ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ១៧៥ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
# ស្តីពី
# ការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៩១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៤៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៨៦ សសរ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញសេចក្តីសម្រេចលេខ ៩៣៣ គ.ជ.ប.ស.ស.រ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ជូនដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

**ប្រការ២.-**

សេចក្តីសម្រេចនេះ មានគោលដៅ ៖

- ជួយដល់អ្នកបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការបានយល់ដឹងអំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការដែលត្រូវប្រើនៅពេលបោះឆ្នោត
- ជួយដល់អ្នកបោះឆ្នោត អាចរកឃើញយ៉ាងងាយស្រួលនូវទីតាំងការិយាល័យបោះឆ្នោតដែលសាមីខ្លួនត្រូវទៅបោះឆ្នោត
- ជួយដល់គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) ក្នុងការស្វែងរកឈ្មោះសាមីអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការបានឆាប់រហ័ស ដែលបង្កភាពងាយស្រួលដល់កិច្ចប្រតិបត្តិការបោះឆ្នោតឱ្យកាន់តែមានភាពរលូន និងមិនឱ្យអ្នកបោះឆ្នោតរង់ចាំយូរ ។

**ប្រការ៣.-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះការចាត់ចែងផលិត និងចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតជូនអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ តាមប្រតិទិនកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ។

## ជំពូកទី២
## ការផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោត

### ផ្នែកទី១
### របៀបផលិត និងទម្រង់បណ្ណព័ត៌មានអ្នកបោះឆ្នោត

**ប្រការ៤.-**

បណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវបានផលិតតាមលក្ខណៈបច្ចេកទេសកុំព្យូទ័រ ដោយការផ្ទេរឈ្មោះ និងទិន្នន័យមួយចំនួនរបស់អ្នកបោះឆ្នោតពីបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

បណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ ត្រូវបានបោះពុម្ពផ្នែកខាងមុខ លើក្រដាសសធម្មតា និងផ្នែកខាងខ្នង លើក្រដាសពណ៌ ។

**ប្រការ៥.-**

បណ្ណព័ត៌មានអ្នកបោះឆ្នោត មានរាងចតុកោណកែងដែលមានបណ្ដោយប្រវែង ១៣.៩សង់ទីម៉ែត្រ និងទទឹងប្រវែង ៦.៣សង់ទីម៉ែត្រ ។ ពណ៌អក្សរដែលត្រូវបោះពុម្ពលើបណ្ណព័ត៌មានអ្នកបោះឆ្នោត អាស្រ័យដោយការកំណត់របស់ គ.ជ.ប ។

## ផ្នែកទី២
## ខ្លឹមសារបណ្ណព័ត៌មានអ្នកបោះឆ្នោត

**ប្រការ៦.-**

ខ្លឹមសារបណ្ណព័ត៌មានអ្នកបោះឆ្នោតផ្នែកខាងមុខ មានដូចតទៅ ៖

- និមិត្តសញ្ញា គ.ជ.ប
- បណ្ណព័ត៌មានអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣
- រូបថតសាមីអ្នកបោះឆ្នោត
- ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន លេខកូដការិយាល័យបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោតអត្តលេខ លេខរៀងក្នុងបញ្ជីបោះឆ្នោត ឈ្មោះរាជធានី ខេត្ត និងឈ្មោះឃុំ សង្កាត់
- សម្គាល់ ៖
    - ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅ**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣** ចាប់ផ្ដើមពីម៉ោង ៧:០០ ព្រឹក រហូតដល់ម៉ោង ៣:០០ រសៀល
    - បណ្ណព័ត៌មាននេះ មិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិ-ខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

**ប្រការ៧.-**

ខ្លឹមសារបណ្ណព័ត៌មានអ្នកបោះឆ្នោតផ្នែកខាងខ្នង មានដូចតទៅ ៖

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយ ដូចខាងក្រោម ៖
- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថាដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះ មកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

សម្គាល់ ៖ - នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលេខ 1800203030 ដោយឥតគិតថ្លៃ ។

# ជំពូកទី៣
# ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

## ផ្នែកទី១
## ភារកិច្ចនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស

**ប្រការ៨.-**

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស មានភារកិច្ចដូចតទៅ ៖

- រៀបចំផលិតបណ្ណព័ត៌មានអ្នកបោះឆ្នោតទៅតាមចំនួនអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ
- វេចខ្ចប់សៀវភៅបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គជ.ខប)
- រៀបចំបណ្តុះបណ្តាល គជ.ខប ឬមន្ត្រីលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគជ.ខប) អំពីរបៀបបែងចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតជូនដល់អ្នកបោះឆ្នោត
- តាមដាន និងត្រួតពិនិត្យការវិវត្តនៃការបែងចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតហើយរាយការណ៍ប្រចាំសប្តាហ៍ជូន គ.ជ.ប
- បូកសរុបរបាយការណ៍ក្រោយពេលបញ្ចប់ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត នៅតាមបណ្តារាជធានី ខេត្តដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប ។

## ផ្នែកទី២
## ភារកិច្ចរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

**ប្រការ៩.-**

គជ.ខប មានភារកិច្ចដូចតទៅ ៖

- ធ្វើទំនាក់ទំនងជាមួយគណៈអភិបាលរាជធានី ខេត្ត និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) និងមេភូមិ ឬជំនួយការភូមិ ឱ្យសហការជាមួយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ក្នុងការអនុវត្តការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

- ធ្វើទំនាក់ទំនងជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីស្នើចាត់បញ្ជូនតំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះទៅក្នុងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមឃុំ សង្កាត់

- ចាត់ចែងផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងខ្លឹមសារបច្ចេកទេសនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ជូន គឃ.សប តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មេភូមិ ឬជំនួយការភូមិពាក់ព័ន្ធ និងតំណាងគណបក្សនយោបាយ

- បណ្តុះបណ្តាល គឃ.សប អំពីរបៀបចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតជូនដល់អ្នកបោះឆ្នោត

- ប្រគល់សៀវភៅបណ្ណព័ត៌មានអ្នកបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ជូន គឃ.សប ដែលមានភារកិច្ចទទួលខុសត្រូវរួមក្នុងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

- ធ្វើរបាយការណ៍រៀងរាល់សប្តាហ៍ អំពីលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត បញ្ជូនមក គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត)

- ត្រួតពិនិត្យនូវរាល់សកម្មភាពរបស់ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងជួយអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុក្នុងពេលចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

- ធ្វើរបាយការណ៍បូកសរុបនៅពេលបញ្ចប់ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត បញ្ជូនមក គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត)

- ធ្វើការងារបច្ចេកទេសផ្សេងទៀតទាក់ទងនឹងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត និងអគ្គលេខាធិការដ្ឋាន គ.ជ.ប ប្រគល់ឱ្យ ។

## ផ្នែកទី៣
## ភារកិច្ចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

**ប្រការ១០.-**

គឃ.សប មានភារកិច្ចដូចតទៅ ៖

- រៀបចំ និងចាត់តាំងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដូចមានចែងក្នុងប្រការ១១ និងប្រការ១២ តាមការចាំបាច់

- ផ្សព្វផ្សាយដល់ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងដល់តំណាងគណបក្សនយោបាយអំពីសេចក្ដីសម្រេចនេះ ខ្លឹមសារបច្ចេកទេសនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ព្រមទាំងសារប្រយោជន៍នៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងខ្លឹមសារដែលត្រូវបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋ

- សហការជាមួយ កបឃ.ស និងមេភូមិ ឬជំនួយការភូមិ ក្នុងការកំណត់ប្រតិទិនសម្រាប់ចុះចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

- ផ្ដល់ព័ត៌មានប្រចាំសប្ដាហ៍ជូន គធ.ខប អំពីលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងហេតុការណ៍កើតមានឡើង ដែលត្រូវស្នើសុំការអន្តរាគមន៍ដោះស្រាយ

- ប្រជុំពិនិត្យបូកសរុបរបាយការណ៍របស់ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅពេលបញ្ចប់ការងារដើម្បីរាយការណ៍ជូន គ.ជ.ប តាមរយៈ គធ.ខប

- រក្សាទុកសៀវភៅបណ្ណព័ត៌មានអ្នកបោះឆ្នោត ដែលនៅសល់ពុំទាន់បានចែកជូនអ្នកបោះឆ្នោត ដើម្បីបន្តចែកជូនអ្នកបោះឆ្នោតរហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣

- ធ្វើរបាយការណ៍តាមការិយាល័យបោះឆ្នោត និងតាមឃុំ សង្កាត់ស្ដីពីការសរុបលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតបន្ត (របាយការណ៍ធ្វើនៅក្រោយពេលបោះឆ្នោត)

- ប្រគល់សៀវភៅបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសល់ជូន កបឃ.ស ដើម្បីរក្សាទុកជាឯកសារ និងជាជំនួយក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតឱ្យកាន់តែមានសុក្រឹតភាពនៅឆ្នាំបន្ទាប់ ។

## ផ្នែកទី៤
## ការបង្កើតក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

### ប្រការ១១._

គឃ.សប ត្រូវចាត់តាំងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតមួយ ឬច្រើនក្រុមឱ្យសមស្របតាមចំនួនភូមិ និងទៅតាមភូមិសាស្ត្រជាក់ស្ដែងក្នុងឃុំ សង្កាត់របស់ខ្លួន ។

### ប្រការ១២._

ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- | សមាជិក គឃ.សប ១ រូប | ជាប្រធាន |
| ២- | សមាជិក កបឃ.ស ១ រូប ឬច្រើនរូប | ជាសមាជិក |
| ៣- | តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ១ រូប ឬច្រើនរូប | ជាសមាជិក (ប្រសិនបើមាន) |
| ៤- | មេភូមិ ឬជំនួយការភូមិពាក់ព័ន្ធ | ជាសមាជិក ។ |

អវត្តមានរបស់តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រុមចែកបណ្ណព័ត៌មានមិនរាំងស្ទះដល់ដំណើរការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតឡើយ ។

**ប្រការ១៣.-**

គណបក្សនយោបាយ និងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនមែនជាសមាជិកក្រុមចែកបណ្ណព័ត៌មាន អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យតាមសង្កេតមើលដំណើរការនៃការចែកបណ្ណព័ត៌មានក្នុងឃុំ សង្កាត់ពាក់ព័ន្ធបាន ។

## ផ្នែកទី៥
## ភារកិច្ចរបស់ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

**ប្រការ១៤.-**

ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត មានភារកិច្ចដូចតទៅ ៖

- ស្រង់ឈ្មោះភូមិដែលទាក់ទងទៅនឹងអាសយដ្ឋានរបស់អ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ រួចកត់ចំណាំនៅលើស្រោមសំបុត្រដាក់បណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីបង្កភាពងាយស្រួលក្នុងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅតាមភូមិនានា ក្នុងឃុំ សង្កាត់
- សហការជាមួយមេភូមិ ឬជំនួយការភូមិពាក់ព័ន្ធដែលជាសមាជិកក្រុមក្នុងការពិនិត្យឈ្មោះអ្នកបោះឆ្នោតនៅក្នុងសៀវភៅបណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា តើគាត់ស្គាល់ឈ្មោះប្រជាពលរដ្ឋទាំងនោះដែរឬទេ ? តើផ្ទះរបស់ប្រជាពលរដ្ឋស្ថិតនៅកន្លែងណា និងក្នុងក្រុមណា ? តើប្រជាពលរដ្ឋមានវត្តមាននៅផ្ទះដែរឬទេ ? ដើម្បីបានដឹងព័ត៌មានច្បាស់លាស់នៅមុនពេលចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
- សហការជាមួយមេភូមិ ឬជំនួយការភូមិពាក់ព័ន្ធដែលជាសមាជិកក្រុមអញ្ជើញប្រជា-ពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឱ្យមកប្រមូលផ្តុំគ្នានៅទីកន្លែងកំណត់ណាមួយដើម្បីប្រជុំផ្សព្វផ្សាយ និងទទួលយកបណ្ណព័ត៌មានអ្នកបោះឆ្នោត ។ ផ្អែកតាមលទ្ធភាពជាក់ស្តែងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតអាចចុះតាមលំនៅឋានប្រជាពលរដ្ឋ ឬ/និងក្នុងភូមិសាស្ត្រភូមិនីមួយៗក្នុងឃុំ សង្កាត់ដើម្បីចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតដោយគ្មានការរើសអើងជូនសាមីអ្នកបោះឆ្នោត ឬតំណាងតាមចំនួន និងឈ្មោះដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់
- កាត់បណ្ណព័ត៌មានដែលត្រូវនឹងឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងទិន្នន័យផ្សេងទៀតរបស់សាមីអ្នកបោះឆ្នោត រួចប្រគល់ជូនសាមីខ្លួន ឬតំណាង
- ចុះចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមភូមិនីមួយៗតាមប្រតិទិនកំណត់ដោយនាំយកទៅជាមួយនូវបណ្ណព័ត៌មានអ្នកបោះឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទាំងអស់
- ធ្វើរបាយការណ៍ប្រចាំថ្ងៃនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតបញ្ជូនទៅ គឃ.សប
- ប្រគល់របាយការណ៍ និងបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសល់ជូន គឃ.សប រក្សាទុកដើម្បីចែកបន្តរហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ។

## ជំពូកទី៤
## រយៈពេលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

**ប្រការ១៥.-**

ការអនុវត្តការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវអនុលោមតាមប្រតិទិនការងារដែលកំណត់ដោយ គ.ជ.ប ។

## ជំពូកទី៥
## ការត្រួតពិនិត្យលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

**ប្រការ១៦.-**

ក្នុងការត្រួតពិនិត្យ វាយតម្លៃលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត គឃ.សប ត្រូវ៖

- តាមដានជាប្រចាំ និងណែនាំក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
- ចុះសាកសួរប្រជាពលរដ្ឋមួយចំនួនដោយផ្ទាល់ នៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីវាយតម្លៃអំពីប្រសិទ្ធភាពនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
- បូកសរុបរបាយការណ៍ជូន គធ.ខប នៅពេលបញ្ចប់ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការណែនាំ ។

**ប្រការ១៧.-**

ក្នុងការត្រួតពិនិត្យ វាយតម្លៃលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត គធ.ខប ត្រូវ៖

- ចុះទៅឃុំ សង្កាត់មួយចំនួនក្នុងរាជធានី ខេត្តដើម្បីត្រួតពិនិត្យលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ក្នុងនោះត្រូវក្ដាប់ឱ្យបាននូវចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និង គឃ.សប បានផ្ដល់ជូនប្រជាពលរដ្ឋ និងចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសល់ (ប្រសិនបើមាន)
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងរាជធានី ខេត្ត ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប ។

**ប្រការ១៨.-**

ក្រោយពីទទួលបានរបាយការណ៍បូកសរុបលទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតពី គធ.ខប នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវបូកសរុបលទ្ធផល នៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅទូទាំងប្រទេស រួចដាក់ជូនអគ្គលេខាធិការពិនិត្យ និងផ្ដល់យោបល់ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច និងចម្លងជូនក្រសួងមហាផ្ទៃ ។

# ជំពូកទី៦
# អវសានប្បញ្ញត្តិ

**ប្រការ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ២០.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប គធ.ខប គឃ.សប កបឃ.ស និងក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃច័ន្ទ ៧រោច ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**កន្លែងទទួល ៖**

- ក្រសួងមហាផ្ទៃ
- គ្រប់សាលារាជធានី ខេត្ត
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
- អង្គការមិនមែនរដ្ឋាភិបាលចូលរួមសង្កេតការណ៍បោះឆ្នោត

  **"ដើម្បីជូនជ្រាប និងសុំកិច្ចសហការគាំទ្រ"**
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ថ្ងៃពុធ ៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

# ប្រតិទិននៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
# សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

| ល.រ | ភារកិច្ចដែលត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការធ្វើតារាងបែងចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី១៥ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ |
| ២ | ការបោះពុម្ព និងការវេចខ្ចប់បណ្ណព័ត៌មានអ្នកបោះឆ្នោត | ថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ |
| ៣ | ការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដល់ គធ.ខប និងបញ្ជូនបណ្ណព័ត៌មានអ្នកបោះឆ្នោតទៅរាជធានី ខេត្ត | ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ |
| ៤ | គធ.ខប ជួបទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្នើសុំការគាំទ្រ | ថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ |
| ៥ | គធ.ខប ផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដល់ គឃ.សប សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ | ថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ |
| ៦ | គឃ.សប ផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដល់ កបឃ.ស មេភូមិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ | ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ |
| ៧ | គឃ.សប តែងតាំងក្រុមចែកបណ្ណព័ត៌មាន និងកំណត់ប្រតិទិនចែកបណ្ណព័ត៌មានតាមភូមិ | ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ |
| ៨ | ក្រុមចែកបណ្ណរៀបចំបណ្ណព័ត៌មាន និងឯកសារត្រៀមចែកបណ្ណព័ត៌មានតាមភូមិ | ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ |
| ៩ | មេភូមិផ្សព្វផ្សាយប្រតិទិនពេលវេលា និងទីកន្លែងចែកបណ្ណព័ត៌មានជូនប្រជាពលរដ្ឋ | ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ |
| ១០ | ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតជូនប្រជាពលរដ្ឋតាមភូមិក្នុងឃុំ សង្កាត់ | ថ្ងៃទី២៤ ខែឧសភា ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ |
| ១១ | ក្រុមបែងចែកប្រគល់របាយការណ៍ និងបណ្ណព័ត៌មាននៅសល់ជូន គឃ.សប | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ |
| ១២ | ការបន្តចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅទីស្នាក់ការ គឃ.សប | ថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ |
| ១៣ | គឃ.សប ត្រួតពិនិត្យ និងរាយការណ៍ប្រចាំសប្តាហ៍ជូន គធ.ខប | ថ្ងៃទី២៤ ខែឧសភា ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ |
| ១៤ | គធ.ខប ត្រួតពិនិត្យ និងរាយការណ៍ប្រចាំសប្តាហ៍ជូន គ.ជ.ប | ថ្ងៃទី២៤ ខែឧសភា ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ |
| ១៥ | គឃ.សប និង គធ.ខប បូកសរុបរបាយការណ៍ជំហានដំបូងជូន គ.ជ.ប | ថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ |
| ១៦ | អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប បូកសរុបលទ្ធផលជំហានដំបូងជូន គ.ជ.ប | ថ្ងៃទី១ ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ |
| ១៧ | គឃ.សប គធ.ខប និងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប បូកសរុបរបាយការណ៍លទ្ធផលបញ្ចប់នៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតជូន គ.ជ.ប | យ៉ាងយូរ ១៤ថ្ងៃ ក្រោយថ្ងៃបោះឆ្នោត |

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : កា គិមហេង
ភេទ : ស្រី
ថ្ងៃខែឆ្នាំកំណើត : 15-05-1966
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 00-000-221
លេខរៀងក្នុងបញ្ជី : ៧
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : កាន់ សុភី
ភេទ : ស្រី
ថ្ងៃខែឆ្នាំកំណើត : 09-09-1962
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 00-000-224
លេខរៀងក្នុងបញ្ជី : ៨
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : កាំង យ៉ានី
ភេទ : ស្រី
ថ្ងៃខែឆ្នាំកំណើត : 12-08-1980
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 12-352-372
លេខរៀងក្នុងបញ្ជី : ៩
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : ភឿន ពន្លក
ភេទ : ប្រុស
ថ្ងៃខែឆ្នាំកំណើត : 07-09-1981
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 00-000-218
លេខរៀងក្នុងបញ្ជី : ១០
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : កេះ កែវ
ភេទ : ប្រុស
ថ្ងៃខែឆ្នាំកំណើត : 13-08-1941
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 00-000-048
លេខរៀងក្នុងបញ្ជី : ១១
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

## បណ្ណព័ត៌មានអ្នកបោះឆ្នោត



### សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

នាមត្រកូល និងនាមខ្លួន : កេះ គិមហឿន
ភេទ : ស្រី
ថ្ងៃខែឆ្នាំកំណើត : 01-04-1962
អាសយដ្ឋាន : ភូមិអូរអណ្ដូងកណ្ដាល
ការិយាល័យបោះឆ្នោត : 0001-វត្តអូរអណ្ដូងកណ្ដាល
អត្តលេខ : 00-000-137
លេខរៀងក្នុងបញ្ជី : ១២
រាជធានី ខេត្ត : បន្ទាយមានជ័យ
ឃុំ សង្កាត់ : បន្ទាយនាង

សម្គាល់ :
- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ចាប់ផ្ដើមពីម៉ោង ៧:00 ព្រឹក រហូតដល់ម៉ោង ៣:00 រសៀល
- បណ្ណព័ត៌មាននេះមិនអាចប្រើប្រាស់ជំនួសអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) បានឡើយ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

☞ សូមភ្ជាប់មកជាមួយនូវ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងក្រោម ៖

- **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព**
- **ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)** ។

☞ សូមពិនិត្យមើលឈ្មោះ និងទិន្នន័យនៅផ្នែកម្ខាងទៀតនៃបណ្ណនេះ ដើម្បីឱ្យប្រាកដថា ដូចគ្នានឹងឈ្មោះ និងទិន្នន័យដែលមាននៅលើ **ឯកសារបញ្ជាក់អត្តសញ្ញាណ** ដែលត្រូវប្រើពេលបោះឆ្នោត ។

☞ សូមយកបណ្ណនេះមកជាមួយនៅពេលបោះឆ្នោត ដើម្បីងាយស្រួលស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកបោះឆ្នោតមិនបានយកបណ្ណនេះមកជាមួយ ឬពុំបានទទួលបណ្ណនេះក៏អាចបោះឆ្នោតបានដែរ ។

**សម្គាល់** ៖- នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មាន **ឯកសារបញ្ជាក់អត្តសញ្ញាណ** ណាមួយដូចខាងលើ មិនអាចបោះឆ្នោតបានឡើយ

- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលេខ 1800203030 ដោយឥតគិតថ្លៃ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# របាយការណ៍ស្ដីពីការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

លើកទី..........

## ១. លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

## ២. សមាសភាពក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត (ក្រុមទី ................)

| ល.រ | គោត្តនាម និងនាម | មុខដំណែង និងអង្គភាព | ឋានៈក្នុងក្រុមចែកបណ្ណព័ត៌មាន |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

## ៣. លទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

| | |
|---|---|
| ក- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតសរុបក្នុងការិយាល័យ | សន្លឹក |
| ខ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណបានចែកសរុប (បូកយោង) | សន្លឹក |
| គ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់ | សន្លឹក |

**សម្គាល់ ៖** ជាធម្មតា គ = ក - ខ

## ៤. សំណូមពរពាក់ព័ន្ធនឹងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត (អាចសរសេរបន្ថែមនៅផ្នែកខាងខ្នង)

..........................................................................................................................................

..........................................................................................................................................

## ៥. ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

កាលបរិច្ឆេទ............./............./.............

តំណាង គឃ.សប　　តំណាង កបឃ.ស　　តំណាងសមាគម ឬ/និងអង្គការមិនមែនរដ្ឋាភិបាល　　មេភូមិ ឬជំនួយការភូមិ

....................　　....................　　....................................(ប្រសិនបើមាន)　　....................

ទម្រង់បែបបទនេះត្រូវបំពេញ ៤ច្បាប់ ១ច្បាប់ ជូន គឃ.សប ១ច្បាប់ ជូន កបឃ.ស ១ច្បាប់ ជូន គធ.ខប និង ១ច្បាប់ ផ្ញើជូន គ.ជ.ប

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

# របាយការណ៍សរុបលទ្ធផលស្តីពីការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

**១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់**

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | |
| ចំនួនភូមិក្នុងឃុំ សង្កាត់ | | ចំនួនការិយាល័យក្នុងឃុំ សង្កាត់ | | | |

**២. ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត**

| | |
|---|---|
| ក្រុមចែកបណ្ណព័តិមានអ្នកបោះឆ្នោតដែល គឃ.សប បានចាត់តាំងមានចំនួន | ក្រុម |

**៣. លទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត**

| | |
|---|---|
| ក- ចំនួនបណ្ណព័តិមានអ្នកបោះឆ្នោតសរុបនៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ | សន្លឹក |
| ខ- ចំនួនបណ្ណព័តិមានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណបានចែកសរុប | សន្លឹក |
| គ- ភាគរយនៃបណ្ណព័តិមានអ្នកបោះឆ្នោតដែលបានចែកធៀបនឹងចំនួនបណ្ណព័តិមានសរុប | ភាគរយ |
| ឃ- ចំនួនបណ្ណព័តិមានអ្នកបោះឆ្នោតនៅសល់ដែល គឃ.សប ត្រូវចែកបន្ត | សន្លឹក |

**សម្គាល់ ៖** ជាធម្មតា គ = (ខ x ១០០) / ក, ឃ = ក - ខ

**៤. សំណូមពរពាក់ព័ន្ធនឹងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត** (អាចសរសេរបន្ថែមនៅផ្នែកខាងខ្នង)

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

**៥. គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត**

កាលបរិច្ឆេទ............/ ............./ ..............

ប្រធាន គឃ.សប      ត្រា (គឃ.សប)      សមាជិក គឃ.សប ទទួលបន្ទុករដ្ឋបាល

....................................................      ....................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# របាយការណ៍ស្តីពីការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ចែកបន្តដោយ គឃ.សប ( គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ )

លើកទី.........

## ១. លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត

| | | | | | |
|---|---|---|---|---|---|
| ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត | | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | | |
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | | |

## ២. លទ្ធផលនៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

| | |
|---|---|
| ក- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតសរុបក្នុងការិយាល័យ | សន្លឹក |
| ខ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណព័ត៌មានចែកបានសរុប | សន្លឹក |
| គ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់ដែល គឃ.សប ត្រូវចែកបន្ត | សន្លឹក |
| ឃ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែល គឃ.សប បានចែកបន្ត (បូកយោង) | សន្លឹក |
| ង- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណ និង គឃ.សប បានចែកសរុប | សន្លឹក |
| ច- ភាគរយនៃបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលបានចែកធៀបនឹងចំនួនបណ្ណសរុប | ភាគរយ |
| ឆ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់ | សន្លឹក |

**សម្គាល់ ៖** ជាជម្មតា គ = ក - ខ,  ង = ខ + ឃ,  ច = (ង x ១០០) / ក,  ឆ = ក - ង

## ៣. សំណូមពរពាក់ព័ន្ធនឹងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត (អាចសរសេរបន្ថែមនៅផ្នែកខាងខ្នង)

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

## ៤. គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

កាលបរិច្ឆេទ............./ ............./ .............

ប្រធាន គឃ.សប    ត្រា (គឃ.សប)    សមាជិក គឃ.សប ទទួលបន្ទុករដ្ឋបាល

..........................................................    ..........................................................

ទម្រង់បែបបទនេះត្រូវបំពេញ ៤ច្បាប់ ១ច្បាប់ ជូន គឃ.សប ១ច្បាប់ ជូន កបឃ.ស ១ច្បាប់ ជូន គធ.ខប និង ១ច្បាប់ ផ្ញើជូន គ.ជ.ប

4
#18

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

## របាយការណ៍សរុបលទ្ធផលស្តីពីការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ចែកបន្តដោយ គឃ.សប ( គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ )

### ១. លក្ខណៈសម្គាល់នៃឃុំ សង្កាត់

| | | | | |
|---|---|---|---|---|
| ឈ្មោះ និងលេខកូដរាជធានី ខេត្ត | | | | |
| ឈ្មោះ និងលេខកូដឃុំ សង្កាត់ | | | | |
| ចំនួនភូមិក្នុងឃុំ សង្កាត់ | | ចំនួនការិយាល័យក្នុងឃុំ សង្កាត់ | | |

### ២. ក្រុមចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត

| | |
|---|---|
| ក- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតសរុបនៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ | សន្លឹក |
| ខ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណព័ត៌មានបានចែកសរុប | សន្លឹក |
| គ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់ដែល គឃ.សប ត្រូវចែកបន្ត | សន្លឹក |
| ឃ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែល គឃ.សប បានចែកបន្តរហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ | សន្លឹក |
| ង- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលក្រុមចែកបណ្ណ និង គឃ.សប បានចែកសរុប | សន្លឹក |
| ច- ភាគរយនៃបណ្ណព័ត៌មានអ្នកបោះឆ្នោតដែលបានចែកធៀបនឹងចំនួនបណ្ណសរុប | ភាគរយ |
| ឆ- ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតនៅសល់ដែលត្រូវប្រគល់ជូន កបឃ.ស | សន្លឹក |

**សម្គាល់៖** ជាធម្មតា គ = ក - ខ,  ង = ខ + ឃ,  ច = (ង x ១០០) / ក,  ឆ = ក - ង

### ៣. សំណូមពរពាក់ព័ន្ធនឹងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត (អាចសរសេរបន្ថែមនៅផ្នែកខាងខ្នង)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

យោបល់របស់ គឃ.សប..........................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

### ៤. គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

កាលបរិច្ឆេទ............/ ............/ ............

ប្រធាន គឃ.សប          ត្រា (គឃ.សប)          សមាជិក គឃ.សប ទទួលបន្ទុករដ្ឋបាល

..................................................................          ..................................................................

ទម្រង់បែបបទនេះត្រូវបំពេញ ៤ច្បាប់ ១ច្បាប់ ជូន គឃ.សប ១ច្បាប់ ជូន កបឃ.ស ១ច្បាប់ ជូន គធ.ខប និង ១ច្បាប់ ផ្ញើជូន គ.ជ.ប